ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| |
|---|
| រដ្ឋបាលរាជធានី ខេត្ត............ |
| រដ្ឋបាលក្រុង ស្រុក ខណ្ឌ........ |
| លេខៈ.................. |

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ ក្រុង ស្រុក ខណ្ឌ

**អភិបាល នៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០១៥ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យ លេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យ លេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យ លេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងលិខិតលេខ៥២៩ ល.ស/គ.ជ.អ.ប ចុះថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- យោងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងផែនការអនុវត្តបីឆ្នាំដំណាក់កាលទី៣ (២០១៨-២០២០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៧



៧

- យោងផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០១៣
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៦-២០១៨ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៦
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣) ចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១៩។
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ខណ្ឌដូចខាងក្រោម៖

| | |
|---|---|
| ១-លោក លោកស្រីអភិបាលរង នៃគណៈអភិបាលខណ្ឌ | ជាប្រធាន |
| ២-លោក លោកស្រី នាយក ឬនាយករងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| ៣-លោក លោកស្រី ប្រធានការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម | សមាជិក |
| ៤-លោក លោកស្រី ប្រធានការិយាល័យអប់រំ យុវជន និងកីឡា | សមាជិក |
| ៥-លោក លោកស្រី ប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក លោកស្រី ប្រធានការិយាល័យច្រកចេញចូលតែមួយ | សមាជិក |
| ៧-លោក លោកស្រី ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៨-លោក លោកស្រី មន្ត្រីបង្គោលគណនេយ្យភាពសង្គម ក្រុង ស្រុក ខណ្ឌ | សមាជិកអចិន្ត្រៃយ៍ |
| ៩-លោក លោកស្រី ប្រធានការិយាល័យប្រជាពលរដ្ឋ | សមាជិក |
| ១០-លោក លោកស្រី មេឃុំ ចៅសង្កាត់គោលដៅ | សមាជិក |
| ១១-តំណាងអង្គការមិនមែនរដ្ឋាភិបាល ដៃគូអនុវត្តការងារគណនេយ្យភាពសង្គម | សមាជិក |

**ប្រការ ២.**_

**ក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ ក្រុង ស្រុក ខណ្ឌមានតួនាទីភារកិច្ចដូចខាងក្រោម៖**

- គាំទ្រក្នុងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹង ការអនុវត្តការងារគណនេយ្យភាពសង្គមដល់រដ្ឋបាលខណ្ឌ សង្កាត់ និងអង្គភាពផ្តល់សេវា មន្ត្រីបង្គោលគណនេយ្យភាពសង្គម ខណ្ឌ សង្កាត់ ស្ថាប័នពាក់ព័ន្ធនានា
- គាំទ្រការអនុវត្តទាំងផ្នែកផ្គត់ផ្គង់(តួអង្គរដ្ឋ) និងផ្នែកតម្រូវការ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិលតាមគោលការណ៍នានា នៃផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងារទូទៅជាមួយស្ថាប័ន មន្ទីរ អង្គភាព និងអង្គការដៃគូអនុវត្តនៅមូលដ្ឋាន
- គាំទ្រការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការងារគណនេយ្យភាពសង្គម



២

- រៀបចំរបាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ ត្រីមាស ឆមាសនិងប្រចាំឆ្នាំ ស្តីពីវឌ្ឍភាព និងបញ្ហាប្រឈមនានា នៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ជូនថ្នាក់ដឹកនាំសម្រាប់រាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សានៅក្នុងពេលអនុវត្ត និងសម្របសម្រួល រវាងផ្នែកផ្គត់ផ្គង់ និង ផ្នែកតម្រូវការ
- រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ជូនរដ្ឋបាលរាជធានី ខេត្ត
- តាមដាន ត្រួតពិនិត្យ និងចូលរួមក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម នៅថ្នាក់ ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់
- រៀបចំប្រជុំទៀងទាត់នូវរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- អនុវត្តតួនាទីភារកិច្ចផ្សេងៗទៀត ពាក់ព័ន្ធនិងការងារគណនេយ្យភាពសង្គម ដែលថ្នាក់ដឹកនាំប្រគល់ជូន

**ប្រការ ៣._**

អភិបាលរង នាយក ឬនាយករងរដ្ឋបាលខណ្ឌ ប្រធានការិយាល័យចំណុះសាលាក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់គោលដៅ និងអស់លោក លោកស្រី ដែលមានក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ..................ខែ.......... ឆ្នាំ.............. ព.ស.២៥៦៤

..................ថ្ងៃទី ខែ ឆ្នាំ២០២.........

**អភិបាល នៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ**

<u>**ចម្លងជូន៖**</u>

-លេខាធិការដ្ឋាន គ.ជ.អ.ប
-ក្រសួងស្ថាប័នពាក់ព័ន្ធ
-រដ្ឋបាលរាជធានី ខេត្ត
-មន្ទីរពាក់ព័ន្ធ
-រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវា
-អង្គការសង្គមស៊ីវិល ដៃគូអនុវត្ត I-SAF
"ដើម្បីជូនជ្រាប"
-ប្រការ១. និងប្រការ៣
"ដើម្បីសហការអនុវត្ត"
-ឯកសារ កាលប្បវត្តិ